**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ:** ០១៥ **គ.ជ.ប**

# គោលការណ៍
## សម្រាប់ការបោះពុម្ព និងផ្សព្វផ្សាយអត្ថបទឃោសនា
## របស់គណបក្សនយោបាយក្នុងព្រឹត្តិបត្រគោលនយោបាយគណបក្ស
## សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤

- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នឹងរៀបចំបោះពុម្ពព្រឹត្តិបត្រគោលនយោបាយគណបក្សចំនួន ពីរ (២) លេខ ក្នុងពេលឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤។

ដើម្បីឱ្យការបោះពុម្ពព្រឹត្តិបត្រនេះប្រព្រឹត្តទៅតាមគោលការណ៍ស្មើភាព គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត មានសិទ្ធិផ្តល់អត្ថបទស្តីពីគោលនយោបាយរបស់គណបក្សខ្លួនមក គ.ជ.ប ដើម្បីធ្វើការបោះពុម្ព និងផ្សព្វផ្សាយជាសាធារណៈដោយឥតគិតថ្លៃ។

គ.ជ.ប សម្រេចនូវគោលការណ៍ស្តីពីការបោះពុម្ពផ្សាយដូចខាងក្រោម៖

### ១. លក្ខខណ្ឌនៃការបោះពុម្ព

១.១ អត្ថបទគោលនយោបាយរបស់គណបក្សត្រូវមានទំហំ A4 (21cm x 29.7cm)

| | | | |
|---|---|---|---|
| Page Setup: | - Top | : | 1.5 cm |
| | - Bottom | : | 1.5 cm |
| | - Left | : | 2.5 cm |
| | - Right | : | 1.5 cm |

១.២ គណបក្សនយោបាយនីមួយៗ ត្រូវផ្ដល់នូវអត្ថបទគោលនយោបាយរបស់ខ្លួនចំនួន ពី ១ (មួយ) ទំព័រ ដល់ ៣ (បី) ទំព័រ A4 ក្នុង ១ (មួយ) លេខ។

១.៣ គណបក្សនយោបាយត្រូវរចនាអត្ថបទឃោសនាឱ្យរួចរាល់មុននឹងផ្ដល់មកឱ្យ គ.ជ.ប។

១.៤ គណបក្សនយោបាយអាចផ្ដល់នូវខ្លឹមសារឃោសនារបស់ខ្លួនជាអត្ថបទក៏បាន ឬជារូបភាព ស ខ្មៅ ស្ដីពីសកម្មភាពរបស់គណបក្សខ្លួនក៏បាន។

១.៥ គណបក្សនយោបាយអាចផ្ដល់ខ្លឹមសារនៃការឃោសនានេះជាឯកសារក្រដាស (Hard Copy) និងជាឯកសារក្នុងកុំព្យូទ័រ (Soft Copy)។

១.៦ គណបក្សនយោបាយនីមួយៗត្រូវផ្ដល់អត្ថបទនៃការឃោសនាមក គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា រហូតដល់ ១៤ (ដប់បួន) ថ្ងៃ យ៉ាងតិច មុនថ្ងៃចាប់ផ្ដើមឃោសនាបោះឆ្នោត។

១.៧ លេខរៀងទំព័រចុះផ្សាយក្នុងព្រឹត្តិបត្រ ត្រូវធ្វើការចាប់ឆ្នោតដោយតំណាងគណបក្សនយោបាយ។

## ២. ការបែងចែក និងការផ្សព្វផ្សាយ

២.១ គណបក្សនយោបាយត្រូវចាត់តំណាងរបស់ខ្លួនមកទទួលយកព្រឹត្តិបត្រគោលនយោបាយនៅ គ.ជ.ប។

២.២ គ.ជ.ប ត្រូវធ្វើការបែងចែក និងផ្សព្វផ្សាយដល់ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ អង្គការសង្កេតការណ៍បោះឆ្នោត ស្ថានទូត អង្គភាពសារព័ត៌មាន និងនៅតាមតូបលក់កាសែតសាធារណៈដោយឥតគិតថ្លៃ។

## ៣. គោលការណ៍ច្បាប់

៣.១ ខ្លឹមសារអត្ថបទឃោសនារបស់គណបក្សនយោបាយ ត្រូវគោរពគោលការណ៍ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៣.២ ក្នុងករណី គ.ជ.ប ពិនិត្យឃើញខ្លឹមសារនៃអត្ថបទឃោសនាប្រាសចាកពីគោលការណ៍ច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ គ.ជ.ប មានសិទ្ធិស្នើឱ្យធ្វើការកែតម្រូវមុននឹងបោះពុម្ពផ្សាយ។

៣.៣ ក្នុងករណីគណបក្សនយោបាយមិនអនុវត្តតាមការស្នើសុំឱ្យកែតម្រូវ គ.ជ.ប មិនចុះផ្សាយនូវអត្ថបទឃោសនានោះឡើយ។

៣.៤ ក្នុងករណីគណបក្សនយោបាយធ្វើសកម្មភាពឃោសនាបោះឆ្នោត ដោយប្រើប្រាស់នូវរាល់សម្ភារឃោសនាបោះឆ្នោតផ្សេងពីសម្ភារឃោសនាបោះឆ្នោត ដូចមានចែងក្នុង

ចំណុច ៦.១៥ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ ដែលគណៈកម្មការសម្របសម្រួលបានពិនិត្យ និងឯកភាពគ្នារួចហើយ គណបក្សនយោបាយសាមី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

៣.៥ គ.ជ.ប មិនទទួលខុសត្រូវចំពោះគណបក្សនយោបាយដែលមិនគោរពតាមចំណុច ១.៥ នៃគោលការណ៍នេះ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែអាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**